**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE COMMISSION OF CAMBODIA

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:..០០១/១២...ឈូនៃ...គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវា ក្នុងវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញប្រកាសលេខ ០០៥/១១ គមក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្ត វិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ
- បានឃើញសំណើសុំកែប្រែថ្លៃសេវាជាត់ទាត់និងទូទាត់ ដែលមានចែងក្នុងវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២
- បានឃើញសំណើសុំបញ្ចុះថ្លៃសេវាប្រតិបត្តិការជួញដូរមូលបត្រ ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ និងថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជាលើកទី២៤ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងប្រការ ១៤ នៃវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធប្រកាសលេខ ០០៥/១១ គមក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២

គាត ឈន់

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០០១/១២ ញុនម.គ.ម.ក.

ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

ស្ដីពី

ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ
របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ប្រការ ១៤ ថ្មី.-**

សមាជិកត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១. ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ទឹកប្រាក់កម្រៃសេវាត្រូវកាត់ក្បៀសមកត្រឹមមួយខ្ទង់) តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

២. អ្នកបង់ថ្លៃសេវាគឺ ក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។

៣. ពេលវេលានៃការបង់ថ្លៃសេវាគឺ នៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១២ ថ្លៃសេវាសម្រាប់ផាត់ទាត់ និងទូទាត់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ចំនុចទី១ ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ)។